| កិច្ចតែងការ | |
|---|---|
| មុខវិជ្ជា | បុរេគណិត |
| ប្រធានបទ | បរិមាណនិងចំនួន<br>(ដកស្រង់ចេញពីសៀវភៅតើនណាជាអ្នកលាបពណ៌មេឃ) |
| ចំណងជើងមេរៀន | ល្បែងក្ដារពណ៌ |
| កម្រិត | មធ្យម ៣០ នាទី |
| គោលបំណង | រាប់ចំនួន លេខ និងយល់ន័យពី ១ ដល់ ៣០ឬលើសពីនេះ |
| បំណិនសម្បទា | រាប់ចំនួនលេខ បន្ថែមបន្ថយ និងយល់ន័យ ពី១ ដល់៣០ ឬលើសពីនេះ |
| ចរិយាសម្បទា | ឈ្លាសវៃ រហាស់រហួន ក្នុងការគិតលេខ និងសហការជួយគ្នា |
| គ្រូបង្រៀន | បោះពុម្ពក្ដារល្បែង និងអ៊ុតវាឱ្យបានស្អាត និងរឹងមាំ |
| កុមារ | |
| រៀបចំ | ក្ដារល្បែង វត្ថុសម្រាប់រាប់ចំនួន គ្រាប់ឡុកឡាក់ |

| សកម្មភាពគ្រូបង្រៀន | មាតិកា | សកម្មភាពសិស្ស |
|---|---|---|

| | | |
|---|---|---|
| 1. បង្ហាញក្មេងៗពីក្ដារល្បែង<br>2. និយាយប្រាប់ក្មេងៗពីពណ៌នៅលើក្ដារល្បែង<br>3. ពន្យល់ច្បាប់នៃការលេងល្បែងនោះ<br>4. បែងចែកក្មេងៗទៅជាក្រុមៗ ដែលមានក្មេងចាប់ពី ២ -៤នាក់ក្នុង១ក្រុម ឬលើសពីនេះ អាស្រ័យលើចំនួនសិស្សរបស់អ្នក។<br>5. ចែកក្ដារល្បែងទៅតាមក្រុមនីមួយៗ វត្ថុរាប់ចំនួន និងគ្រាប់ឡុកឡាក់<br>6. អនុញ្ញាតឱ្យក្មេងៗទាំងអស់ចាប់ផ្ដើមលេងល្បែងនោះ រហូតដល់អស់ម៉ោងឈប់លេងជាការស្រេច | ច្បាប់<br>1. ជ្រើសរើសវត្ថុសម្រាប់រាប់ចំនួន និងដាក់វានៅចំណុចចាប់ផ្ដើមនៃក្ដារ<br>2. នៅពេលដែលក្មេងទី១នោះរមៀលគ្រាប់ឡុកឡាក់បានលេខប៉ុន្មាន នោះក្មេងត្រូវចាប់ផ្ដើមរាប់ពីពាក្យថាចាប់ផ្ដើមនៅលើសន្លឹកក្ដារពណ៌នោះ ទៅតាមចំនួនរបស់គ្រាប់ឡុកឡាក់ដែលគេរមៀលបាន។<br>3. និងឱ្យក្មេងៗមើលទៅលើពណ៌ ក្នុងប្រអប់ដែលក្មេងៗដើរដល់ និងឱ្យក្មេងនោះ និយាយពី វត្ថុ ឬសម្ភារដែលមានពណ៌ដូចទៅនឹងពណ៌ដែលពួកគេបានដើរដល់ នោះ។ ឧ. ក្មេងទី១នោះ ពណ៌ក្រហម ដូច្នេះ ក្មេងនោះត្រូវនិយាយ ៖ ខ្ញុំស្រឡាញ់កាបូបពណ៌ក្រ | 1. ស្ដាប់ដោយយកចិត្តទុកដាក់នៅពេលដែលគ្រូរបស់អ្នកពន្យល់ពីការលេងល្បែងនេះ និងអ្នកគួរតែសួរគ្រូរបស់អ្នក នៅពេលដែលអ្នកមិនច្បាស់ ឬមិនយល់ពីល្បែង។ ព្រោះវាទាមទារឱ្យអ្នកទាំងអស់គ្នាយល់ឱ្យច្បាស់ដើម្បីលេងល្បែងបានយ៉ាងសប្បាយ<br>2. បោះគ្រាប់ឡុកឡាក់ និងរំកិលវត្ថុរាប់ចំនួនតាមចំនួនរបស់គ្រាប់ឡុកឡាក់ដែលអ្នកបានបោះ<br>3. និយាយប្រាប់ពីសម្ភារប្រើប្រាស់ដែលមានពណ៌ដូចនឹងពណ៌ដែលអ្នកបានដាក់លើនោះ<br>4. ជួយមិត្តរួមថ្នាក់ប្រសិនបើពួកគេត្រូវការអ្នក<br>5. ធ្វើតាមច្បាប់លេងល្បែង និងរីករាយជាមួយវាដោយសប្បាយ |

| | | |
|---|---|---|
| | ហមរបស់ខ្ញុំណាស់ជាដើម។<br>4. បន្ទាប់មកប្តូរវេនទៅក្មេងទី២ម្តងធ្វើដូចគ្នានឹងក្មេងទី២ដែរ។<br>5. ក្មេងណាដែលដើរបានដល់ប្រអប់រូបផ្កាយ ពួកគេអាចឡើងហួស១ ឬ២ប្រអប់ទៅតាមការកំណត់របស់អ្នក។<br>6. ក្មេងណាដែលបានដើរដល់ពណ៌ដែលមានរូបព្រួញស៊ិយ ក្មេងនោះត្រូវធ្លាក់ចុះមកក្រោយវិញតាមសញ្ញាព្រួញស៊ិយហ្នឹងដូចគ្នា។<br>7. ធ្វើដូចនេះរហូតដល់ក្មេងណាដែលបានដើរទៅដល់ចុងក្រោយរូបមករាមុននឹងក្លាយជាអ្នកឈ្នះតែម្តង។ | |